# សិក្ខាសាលា IDWF-ILO/PROMOTE
# ការបណ្តុះបណ្តាល ស្តីពី
# ការដោះស្រាយបញ្ហាពលកម្មកុមារក្នុងការងារតាមផ្ទះ នៅអាស៊ី
# ខែកុម្ភៈ ឆ្នាំ២០១៨, ទីក្រុង កាត្មាន់ឌុ ប្រទេសណេប៉ាល់

Handout H1.3 - **The rights of the child: international and national laws on child labour and children and youth in domestic work** *(adapted for the workshop)*

ឯកសារ H1.3 - **សិទ្ធិកុមារ៖ ច្បាប់អន្តរជាតិនិងច្បាប់ជាតិ ស្តីពីពលកម្មកុមារ និង កុមារនិងយុវជនក្នុងការងារតាមផ្ទះ** (សម្រួលសម្រាប់សិក្ខាសាលា)

## 1. ហេតុអ្វីមានជាច្បាប់សំខាន់?

ច្បាប់ គឺជាវិធាន ដែលចងមនុស្សទាំងអស់ដែលរស់នៅក្នុងសហគមន៍ណាមួយ។ ច្បាប់ជាតិ ការពារសុវត្ថិភាពទូទៅរបស់យើង និងការពារសិទ្ធិរបស់យើង។ ច្បាប់ លើកកម្ពស់អំពើល្អទូទៅ ផ្តល់ដំណោះស្រាយដោយសន្តិវិធី នៅពេលមានជម្លោះ និងផ្តល់សេវាកម្មជាក់លាក់ដល់សង្គម និងដល់បុគ្គលនៅក្នុងសង្គមនោះ។ មានច្បាប់ជាតិ ច្បាប់អន្តរជាតិ ក៏ដូចជាច្បាប់តំបន់ ច្បាប់ខេត្ត ច្បាប់មូលដ្ឋាន (ជួនកាល គេហៅថា បទប្បញ្ញត្តិ ឬវិធាន) ដែលគ្របដណ្តប់តំបន់ជាក់លាក់។

បញ្ហានានាទាក់ទងនឹងពិភពការងារ តែងមានប្បញ្ញត្តិនៅក្នុងច្បាប់ការងារឬក្រមការងារថ្នាក់ជាតិ។ សិទ្ធិនិងភារកិច្ច របស់កម្មករនិងនិយោជក មានចែងនៅក្នុងច្បាប់ទាំងនោះ ដូចការទទួលខុសត្រូវរបស់រដ្ឋាភិបាលដែរ។ *ច្បាប់ទាំងនេះ តែងមានបទប្បញ្ញត្តិអំពីអាយុអប្បបរមាសម្រាប់ការងារនិងវិធានការការពារសម្រាប់កុមារនិងអ្នកធ្វើការវ័យក្មេង។*

ជាទូទៅ ច្បាប់ការងាររបស់ប្រទេសភាគច្រើនបំផុត គ្របដណ្តប់តែទៅលើអ្នកធ្វើការនៅក្នុងវិស័យសាធារណៈនិងឯកជនផ្លូវការ (មន្ត្រីរាជការ អ្នកធ្វើការក្នុងធនាគារ រោងចក្រ សំណង់ សណ្ឋាគារនិងភោជនីយដ្ឋាន គិលានុបដ្ឋាក គ្រូបង្រៀន ជាដើម) ប៉ុណ្ណោះ។ *ដោយសារតែអ្នកធ្វើការភាគច្រើន (រួមមានទាំង អ្នកធ្វើការតាមផ្ទះផង) ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ស្ថិតនៅក្នុងវិស័យក្រៅប្រព័ន្ធនោះ សហជីពនិងអង្គការរបស់អ្នកធ្វើការ បានធ្វើយុទ្ធនាការអស់រយៈពេលជាច្រើនឆ្នាំ ដើម្បីធ្វើឲ្យវិស័យទាំងនេះជាវិស័យផ្លូវការក្នុងប្រព័ន្ធ ដើម្បីឲ្យអ្នកធ្វើការនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ទទួលបានឋានៈនិងសិទ្ធិស្មើគ្នា ដូចអ្នកធ្វើការនៅក្នុងប្រព័ន្ធដែរ។* ព្រឹត្តិការណ៍ជាគោលសំខាន់ៗនៅក្នុងយុទ្ធនាការទូទាំងពិភពលោកនេះ ត្រូវបានរៀបចំឡើងដើម្បីឲ្យមានការអនុម័តអនុសញ្ញា ILO លេខ ១៧៧ ស្តីពីការងារផ្ទះ ក្នុងឆ្នាំ១៩៩៦, អនុសញ្ញា ILO លេខ ១៨៩ ស្តីពីការងារតាមផ្ទះក្នុងឆ្នាំ២០១១ និង អនុសាសន៍អង្គការ ILO លេខ ២០៤ ស្តីពីការផ្ទេរពីសេដ្ឋកិច្ចក្រៅប្រព័ន្ធទៅសេដ្ឋកិច្ចផ្លូវការ ឆ្នាំ២០១៥។

*ប្រទេសភាគច្រើនមានច្បាប់សម្រាប់ការពារកុមារ រួមទាំងអ្នកធ្វើការជាកុមារផង ឲ្យជៀសផុតពីការរំលោភបំពាននិងការកេងប្រវ័ញ្ច។* ប្រទេសផ្សេងទៀត មានច្បាប់ជាក់លាក់ស្តីពីពលកម្មកុមារ ដោយផ្អែកលើអនុសញ្ញា ILO និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ។

## 2. អនុសញ្ញា ILO

អនុសញ្ញាអង្គការពលកម្មអន្តរជាតិ (ILO), ដែលជាទីភ្នាក់ងារអង្គការសហប្រជាជាតិគ្របដណ្តប់លើពិភពការងារ ផ្តល់នូវក្របខណ្ឌសម្រាប់ច្បាប់ជាតិស្តីពីការការពារកុមារនៅកន្លែងធ្វើការ និងស្តីពីពលកម្មកុមារ។ *មានអនុសញ្ញា ILO ចំនួនបី ដែលដោះស្រាយទៅលើបញ្ហាពលកម្មកុមារនៅក្នុងការងារតាមផ្ទះ*

- អនុសញ្ញា ILO លេខ ១៣៨ (១៩៧៣) ស្តីពីអាយុអប្បបរមាសម្រាប់ធ្វើការងារ
- អនុសញ្ញា ILO លេខ ១៨២ (១៩៩៩) ស្តីពីទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ
- អនុសញ្ញា ILO លេខ ១៨៩ (២០១១) ស្តីពីការងារតាមផ្ទះ

អនុសញ្ញា ILO លេខ ១៣៨ គឺជាច្បាប់អន្តរជាតិមួយ ដើម្បីលុបបំបាត់ពលកម្មកុមារ។ នៅពេលដែលផ្តល់សច្ចាប័នដល់អនុសញ្ញានេះហើយ រដ្ឋនិមួយៗ ត្រូវទទួលខុសត្រូវក្នុងការគោរពនិងអនុវត្តវានៅក្នុងច្បាប់និងនៅក្នុងការអនុវត្តជាក់ស្តែង។ អនុសញ្ញានេះ ទាមទារឲ្យរដ្ឋដែលបានផ្តល់សច្ចាប័នហើយ ត្រូវបង្កើនអាយុអប្បបរមាតាមការវិវត្តន៍ សម្រាប់ការអនុញ្ញាតឲ្យផ្តល់ការងារឬចូលធ្វើការ។

អនុសញ្ញា ILO លេខ ១៨២ គឺជាច្បាប់អន្តរជាតិមួយដែលហាមឃាត់និងលុបបំបាត់ "ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ" ជាបន្ទាន់។

អនុសញ្ញា ILO លេខ ១៨៩ ទទួលស្គាល់ថា៖ ក) ការងារតាមផ្ទះ គឺជា ការងារ, ខ) ដូច្នេះ អ្នកធ្វើការងារតាមផ្ទះ គួរមានសិទ្ធិដូចគ្នាទៅនឹងអ្នកធ្វើការងារផ្សេងទៀតដែរ និង គ) តាមលក្ខណៈនៃការងាររបស់ពួកគេនិងកន្លែងដែលពួកគេធ្វើការងារនោះ អ្នកធ្វើការងារតាមផ្ទះ ត្រូវការកិច្ចការពារជាក់ជាក់។ អនុសញ្ញានេះ បានរៀបរាប់នូវសិទ្ធិនិងគោលការណ៍ជាមូលដ្ឋាន និងតម្រូវឲ្យរដ្ឋាភិបាលចាត់វិធានការជាប់ជាបន្តបន្ទាប់ សំដៅធ្វើឲ្យការងារល្អប្រសើរ ក្លាយទៅជាការពិតសម្រាប់អ្នកធ្វើការតាមផ្ទះ។

*អនុសញ្ញា ILO លេខ ១៣៨ និង ១៨២ ត្រូវបានប្រទេសជាច្រើននៅអាស៊ី/ប៉ាស៊ីហ្វិក ផ្តល់សច្ចាប័នរួចហើយ។ មកទល់នឹងពេលបច្ចុប្បន្ននេះ មានតែប្រទេសហ្វីលីពីនមួយគត់ដែលបានផ្តល់សច្ចាប័នអនុសញ្ញា ILO លេខ ១៨៩។* ការផ្តល់សច្ចាប័នលើអនុសញ្ញានេះ គឺជាជំហានយ៉ាងសំខាន់ក្នុងការលើកកម្ពស់លក្ខខណ្ឌការងារល្អប្រសើរ សម្រាប់កម្មករធ្វើការតាមផ្ទះគ្រប់អាយុ។

## 3. អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (CRC)

*ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ កុមារមានសិទ្ធិមនុស្សចំនួនពីរប្រភេទ៖*

ក. ទីមួយ *កុមារមានសិទ្ធិជាមូលដ្ឋានទូទៅដូចមនុស្សពេញវ័យដែរ ទោះបីជាសិទ្ធិខ្លះ ដូចជាសិទ្ធិរៀបអាពាហ៍ពិពាហ៍ មិនអាចអនុវត្តបានរហូតដល់ពេលដែលពួកគេគ្រប់វ័យរៀបការ។*

ខ. ទីពីរ *កុមារមានសិទ្ធិមនុស្សពិសេស ដែលមានភាពចាំបាច់ ដើម្បីការពារពួកគេក្នុងពេលនៅតូច គឺថា រហូតដល់អាយុ១៨ឆ្នាំ។*

សិទ្ធិមនុស្សពិសេសរបស់កុមារ រួមមានដូចជា សិទ្ធិរស់រានមានជីវិត សិទ្ធិមានឈ្មោះ សិទ្ធិទទួលបានការការពារពីការកេងប្រវ័ញ្ចសេដ្ឋកិច្ចនិងផ្លូវភេទ សិទ្ធិទទួលបានការអប់រំ សិទ្ធិបញ្ចេញទស្សនៈយោបល់របស់ខ្លួនទៅលើបញ្ហាដែលពាក់ព័ន្ធនឹងកុមារ សិទ្ធិទទួលបានសេរីភាពគំនិត សតិសម្បជញ្ញៈ និងសាសនា ព្រមទាំងសិទ្ធិទទួលបានការថែទាំសុខភាព ជាដើម។

*សិទ្ធិកុមារ គឺជាបញ្ញត្តិមួយថ្មី។* វាទើបតែនៅក្នុងសតវត្សទី១៩-២០នេះទេ ដែលគេចាប់ផ្តើមពិចារណាអំពីសិទ្ធិកុមារ។ មុនពេលនោះ គេចាត់ទុកកុមារជាទ្រព្យសម្បត្តិរបស់ឪពុកម្តាយឬមនុស្សចាស់ ហើយមនុស្សពេញវ័យ "ក្មេង/តូច" ត្រូវនៅក្រោមការត្រួតត្រារបស់មនុស្សពេញវ័យ "ធំ/ចាស់"។ ដំបូង ការពិភាក្សាអំពីសិទ្ធិកុមារ ផ្តល់ភាគច្រើនទៅលើសិទ្ធិទទួលបានការការពារ ដូចជា ការដាក់ពលកម្មកុមារជាការខុសច្បាប់ (ដែលសូម្បីតែនៅពេលនោះមានការរីករាលដាលរួចទៅហើយ) ជាជាងការពិភាក្សាអំពីការដែលកុមារត្រូវទទួលបានសិទ្ធិដូចពលរដ្ឋដែលមានភាពស្មើគ្នាក្នុងពិភពលោក។

ក្នុងឆ្នាំ១៩២៤ សម្ព័ន្ធប្រជាជាតិ មុនការចាប់កំណើតអង្គការសហប្រជាជាតិ បានអនុម័តសេចក្តីប្រកាសដំបូងស្តីពីសិទ្ធិកុមារ។ សេចក្តីប្រកាសលើកទីពីររបស់អង្គការសហប្រជាជាតិ ត្រូវបានអនុម័ត៣៥ឆ្នាំក្រោយមក គឺក្នុងឆ្នាំ១៩៥៩។ គេបានចំណាយពេល៣០ឆ្នាំ ក្នុងការពិភាក្សានិងដេញដោលវែកញែកទូទាំងសាកលលោក មុនពេលដែល*អង្គការសហប្រជាជាតិអនុម័តអនុសញ្ញាស្តីពីសិទ្ធិកុមារ ក្នុងឆ្នាំ១៩៨៩។* អនុសញ្ញាស្តីពីសិទ្ធិកុមារដែលត្រូវបានប្រទេសស្ទើរតែ**ទាំងអស់**បានផ្តល់សច្ចាប័នហើយនោះ គឺជាឧបករណ៍ដ៏ពិសេសមួយ គឺថាជាច្បាប់អន្តរជាតិមួយដែលប្រមូលស្តង់ដារជាសាកលទាក់ទងនឹងសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គមកិច្ច និងសិទ្ធិមនុស្សធម៌ របស់កុមារ។ ច្បាប់នេះបញ្ជាក់ច្បាស់ថា កុមារត្រូវទទួលបានមិនមែនត្រឹមតែសិទ្ធិមនុស្សរបស់ខ្លួននោះទេ វាថែមទាំងត្រូវទទួលបានសិទ្ធិពិសេស និងការការពារពិសេស ដោយសារតែតម្រូវការពិសេសរបស់ពួកគេ។ ប្រទេសទាំងឡាយ មានកាតព្វកិច្ចក្នុងរាយការណ៍តាមកាលកំណត់ទៅកាន់គណៈកម្មាធិការសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ។ ដោយផ្អែកតាមរបាយការណ៍ទាំងនោះ គណៈកម្មាធិការធ្វើការវាយតម្លៃអំពីរបៀបដែលប្រទេសទាំងនោះ អនុវត្តបទប្បញ្ញត្តិក្នុងអនុសញ្ញាសិទ្ធិកុមារ និងផ្តល់ការណែនាំសម្រាប់ការកែលម្អទៅលើការអនុវត្តរបស់ប្រទេសទាំងនោះ។

អនុសញ្ញានេះ មាន៥៤មាត្រា។ *មាត្រា៣២ ចែងជាពិសេស ស្តីពីពលកម្មកុមារ។* ផ្អែកតាមអនុសញ្ញាអង្គការ ILO, អនុសញ្ញាសិទ្ធិកុមារ អំពាវនាវដល់ប្រទេសទាំងអស់ឲ្យ៖

ក) ទទួលស្គាល់សិទ្ធិកុមារក្នុងការទទួលបានការការពារ៖

- ពីការកេងប្រវ័ញ្ចសេដ្ឋកិច្ច និង
- ពីការធ្វើការងារណាមួយ ដែលទំនងជាអាច៖
    - មានគ្រោះថ្នាក់
    - រំខានដល់ការអប់រំរបស់កុមារ ឬ

- បង្កការខូចខាតដល់សុខភាពរបស់កុមារ ឬដល់ការអភិវឌ្ឍន៍ផ្លូវកាយ ផ្លូវចិត្ត ផ្លូវស្មារតី ផ្នែកសីលធម៌ ឬផ្នែកសង្គម

ខ) ចែងអំពីអាយុអប្បបរមា ឬអាយុអប្បបរមា សម្រាប់ការអនុញ្ញាតិក្នុងការផ្តល់ការងារ

គ) ចែងអំពីការកំណត់ចំនួនម៉ោង និងលក្ខខណ្ឌនៃការផ្តល់ការងារ, និង

ឃ) ចែងអំពីការដាក់ទោសទណ្ឌឲ្យបានសមស្របឬអំពីទណ្ឌកម្មផ្សេងទៀត ដើម្បីធានាឲ្យមានការពង្រឹងការអនុវត្តបទប្បញ្ញត្តិដែលបានលើកឡើងខាងលើ។

*មាត្រា២៨ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ចែងជាពិសេសអំពីការអប់រំ។* មាត្រានេះ អំពាវនាវដល់ប្រទេសទាំងអស់ឲ្យទទួលស្គាល់សិទ្ធិកុមារក្នុងការទទួលបានការអប់រំ និងត្រូវ៖

- ដាក់ការអប់រំថ្នាក់បឋមសិក្សាជាកាតព្វកិច្ច អាចរកបាន និងមិនបង់កម្រៃសម្រាប់ទាំងអស់គ្នា
- ចាត់វិធានការក្នុងការលើកទឹកចិត្តដល់ការទៅរៀនជាទៀងទាត់នៅសាលា និងកាត់បន្ថយអាត្រាបោះបង់ការសិក្សា

## 4. ច្បាប់ វិធាន បទប្បញ្ញត្តិថ្នាក់ជាតិ ស្តីពីការងារតាមផ្ទះ

ច្បាប់ការងាររបស់ប្រទេសភាគច្រើនបំផុតនៅអាស៊ី/ប៉ាស៊ីហ្វិក បានកំណត់អាយុអប្បបរមាសម្រាប់ការផ្តល់ការងារ និងចែងអំពីលក្ខខណ្ឌដែលកុមារអាចធ្វើការបាន។ ក៏ប៉ុន្តែ *មានប្រទេសចំនួនតិចតួចប៉ុណ្ណោះនៅក្នុងតំបន់នេះ ដែលមានច្បាប់សម្រាប់ការពារអ្នកធ្វើការងារតាមផ្ទះ មនុស្សពេញវ័យ និងកុមារ។ នេះគឺដោយសារតែការងារតាមផ្ទះ នៅតែត្រូវគេចាត់ចូលជាប្រភេទការងារក្រៅប្រព័ន្ធ ហេតុដូច្នេះហើយ ត្រូវស្ថិតនៅក្រៅការគ្របដណ្តប់របស់ច្បាប់ការងារ។*

មានការកើនឡើងនូវវិធាននិងបទប្បញ្ញត្តិកម្រិតតំបន់និងកម្រិតមូលដ្ឋាន ក្នុងការការពារអ្នកធ្វើការជាកុមារនិងជាយុវវ័យ។ វិធាននិងបទប្បញ្ញត្តិទាំងនេះមួយចំនួន មានប្រសិទ្ធភាពក្នុងការពារកុមារនិងយុវជនក្នុងការងារតាមផ្ទះ។

## 5. ការយកច្បាប់ទៅអនុវត្ត៖ បញ្ហាប្រឈម

បញ្ហានៅត្រង់ថា ច្បាប់ក្នុងប្រទេសជាច្រើន រួមទាំងនៅអាស៊ី/ប៉ាស៊ីហ្វិច បន្តមានតែនៅលើក្រដាសតែប៉ុណ្ណោះ។ *មានការងារជាច្រើនដែលត្រូវធ្វើ ដើម្បីយកច្បាប់ វិធាន និងបទប្បញ្ញត្តិ ព្រមទាំងអនុសញ្ញាទាំងនោះ ឲ្យក្លាយទៅជាគោលនយោបាយនិងសកម្មភាពប្រកបដោយប្រសិទ្ធភាព រួមទាំង ការដាក់ទោសប្បញ្ញត្តិនិងការដាក់ទណ្ឌកម្ម សម្រាប់ការមិនអនុលោមតាម។* មានបញ្ហាប្រឈមជាច្រើនដែលត្រូវជំនះ រួមមានដូចជា៖

**<u>ឥរិយាបទរាលដាល</u>**

នៅក្នុងសង្គមភាគច្រើនបំផុត មានទស្សនៈដ៏សាយភាយថា ឪពុកម្តាយ (ឬអាណាព្យាបាល) គឺជាអ្នកដែលធ្វើការសម្រេចចិត្តជំនួសកូន សូម្បីតែការសម្រេចចិត្តទាំងនោះ ធ្វើឲ្យមានគ្រោះថ្នាក់ដល់សុខមាលភាពផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសីលធម៌របស់កូនក៏ដោយ និងមិនដើម្បីឧត្តមប្រយោជន៍របស់កូនក៏ដោយ។ ឧទាហរណ៍ ការសម្រេចចិត្តក្នុងការបញ្ជូនកូនទៅធ្វើការ ជំនួសឲ្យការទៅសាលារៀន គឺច្បាស់ណាស់ ថាមិនបានជាឧត្តមប្រយោជន៍

របស់កូនឡើយ។ អនុសញ្ញាស្តីពីសិទ្ធិកុមារនិងអនុសញ្ញា ILO ចែងថា ការធ្វើបែបនេះ គឺជាការរំលោភបំពានសិទ្ធិកុមារ ហើយច្បាប់នៅក្នុងប្រទេសជាច្រើនបានហាមឃាត់ការធ្វើបែបនេះ។

**ជំហរទន់ខ្សោយនិងឋានៈទាបរបស់កុមារ**

ជំហរទន់ខ្សោយនិងឋានៈទាប ដែលជាប់មកជាមួយកុមារនេះ គឺជាក្តីបារម្ភជាក់លាក់មួយ។ ស្ថានភាពនេះកាន់តែមានភាពអាក្រក់ឡើង ដោយសារតែការបដិសេធជាទូទៅ ក្នុងការចាត់ទុកកុមារធ្វើការតាមផ្ទះ ជាអ្នកធ្វើការ និងដោយសារតែសាវតាសង្គមនិងសេដ្ឋកិច្ចដែលទទួលបានការយកចិត្តទុកដាក់តិចតួច។ ជាលទ្ធផល *កុមារ គ្មានសម្លេង មានឥទ្ធិពលតិចតួច និងមានការលំបាកខ្លាំងក្នុងការទាមទារសិទ្ធិរបស់ខ្លួន។*

**ក្របខណ្ឌច្បាប់ ការពង្រឹងការអនុវត្ត និងការតាមដាន**

ពាសពេញអាស៊ី/ប៉ាស៊ីហ្វិក មានបញ្ហាជាច្រើនទាក់ទងដល់ច្បាប់ ដូចមានខាងក្រោមនេះ៖

- ជាទូទៅ *ការងារតាមផ្ទះរបស់កុមារ ត្រូវបានគេមើលឃើញថាជាផ្នែកមួយនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ។* ដូច្នេះហើយ វាបន្តស្ថិតនៅក្រៅវិសាលភាពនៃច្បាប់ការងាររបស់ប្រទេស សូម្បីតែច្បាប់ស្តីពីពលកម្មកុមារមានជាទូទៅហើយក៏ដោយ។ ឧទាហរណ៍ នៅក្នុងប្រទេសឥណ្ឌា ច្បាប់ស្តីពីពលកម្មកុមារ (ការហាមឃាត់និងនិយ័តកម្ម) មិនបានបញ្ចូលកុមារធ្វើការងារតាមផ្ទះទេ ដោយសារតែច្បាប់ការងារនៅថ្នាក់ជាតិ មិនបានចែងច្បាស់លាស់អំពីការងារតាមផ្ទះ ឬការផ្តល់ការងារក្នុងគ្រួសារ។ ជាងនេះទៀត ការពិនិត្យមើលលើច្បាប់ទាក់ទងនឹងពលកម្មកុមារ ផ្តល់នូវចំណាប់អារម្មណ៍មួយថា រដ្ឋាភិបាលមិនបានពិចារណាចាត់ទុក ការងារតាមផ្ទះរបស់កុមារជាការងារខុសច្បាប់ ឬចាត់ចូលជាទម្រង់ដែលមានគ្រោះថ្នាក់នៃពលកម្មកុមារ ដែលត្រូវការដាក់បញ្ញត្តិឬហាមឃាត់នោះទេ។
- *ស្ទើរតែគ្រប់ប្រទេសទាំងអស់នៅអាស៊ី/ប៉ាស៊ីហ្វិក* (លើកលែងប្រទេសឥណ្ឌានិងប្រទេសមួយចំនួនតូចទៀត) *បានផ្តល់សច្ចាប័នអនុសញ្ញា ILO ១៨២ ស្តីពីទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ។* អនុសញ្ញានេះអំពាវនាវដល់ប្រទេសទាំងនោះ *ឲ្យរៀបចំជាបញ្ជីនៃប្រភេទគ្រោះថ្នាក់ដែលគួរដាក់បញ្ចូលទៅក្នុងទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ ប៉ុន្តែប្រទេសជាច្រើននៅតែមិនទាន់បានអនុលោមតាមកាតព្វកិច្ចនេះនៅឡើយទេ។* ហើយនៅក្នុងប្រទេសជាច្រើន កុមារអាយុ១៦-១៧ឆ្នាំ មិនត្រូវបានគេដកចេញពីបញ្ជីជនដែលត្រូវការពារឲ្យរួចផុតពីការងារដែលមានគ្រោះថ្នាក់ឡើយ ដែលជាការទុកឲ្យពួកគេស្ថិតក្នុងភាពងាយរងគ្រោះក្រោមទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ។
- *ការពង្រឹងការអនុវត្តច្បាប់ស្តីពីពលកម្មកុមារ* នៅតែជាបញ្ហាប្រឈមមួយនៅក្នុងប្រទេសជាច្រើន ដោយសារតែ *កង្វះអ្នកធ្វើអធិការកិច្ចការងារ និងកង្វះធនធានគ្រប់គ្រាន់ក្នុងការអនុវត្តការតាមដានឲ្យបានសមស្របទៅអ្នកធ្វើការជាកុមារ* ដោយរួមទាំងកង្វះការបណ្តុះបណ្តាលអ្នកធ្វើអធិការកិច្ចនិងអ្នកតស៊ូមតិ។ ក្នុងករណីពលកម្មកុមារក្នុងការងារតាមផ្ទះ *ការលំបាកចម្បង គឺការតាមដានកន្លែងធ្វើការ ដែលជាផ្ទះឯកជន។* ចំណុចនេះ បានបង្ខំឲ្យអាជ្ញាធរដើរតួនាទីជាអ្នកប្រតិកម្ម ជាជាងតួនាទីគិតគូរសកម្ម ក្នុងការទប់ស្កាត់ការរំលោភបំពាននិងការកេងប្រវ័ញ្ចកុមារធ្វើការតាមផ្ទះទៅវិញ។ ហេតុដូច្នេះហើយ *វាជាតម្រូវការបន្ទាន់ក្នុងការបង្កើតប្រព័ន្ធតាមដានតាមសហគមន៍និងធ្វើឲ្យវាក្លាយទៅជាលក្ខណៈស្ថាប័ន សម្រាប់ការប្រមូលព័ត៌មាន និងទិន្នន័យ ដើម្បីកំណត់រកឲ្យឃើញកុមារធ្វើការតាមផ្ទះ និងតាមដានស្ថានភាពរបស់ពួកគេ។* កិច្ចសហ

ប្រតិបត្តិការរវាងមន្ត្រីថ្នាក់ស្រុក/មូលដ្ឋាន សមាគមម្ចាស់ផ្ទះ និងក្រុមសាសនា/ព្រះវិហារតាមមូលដ្ឋាន ដើម្បី **ការទប់ស្កាត់ ការតាមចាប់មុខសញ្ញា និងការតាមដាន** គួរមានការលើកទឹកចិត្ត។ ពួកគេគឺជាអ្នកដែលមានមធ្យោបាយទាក់ទងនិងដឹងអំពីទំនាក់ទំនងរវាងកុមារធ្វើការតាមផ្ទះនិងនិយោជក។ **នៅទីនេះ មនុស្សពេញវ័យធ្វើការតាមផ្ទះ ជាពិសេសអ្នកដែលធ្វើការជាមួយកុមារឬជិតកុមារ អាចដើរតួនាទីសំខាន់។**

- *ការដាក់ទណ្ឌកម្មព្រហ្មទណ្ឌខ្លាំង និងការដាក់ទោសប្បញ្ញត្តិសម្រាប់ការមិនអនុលោម ត្រូវតែមានវែង* ប្រសិនបើចង់ឲ្យច្បាប់ វិធាន និងបទប្បញ្ញត្តិទាំងនោះ មានប្រសិទ្ធភាព។ ក្នុងប្រទេសហ្វីលីពីន អ្នកតស៊ូមតិដើម្បីសិទ្ធិអ្នកធ្វើការងារតាមផ្ទះ បានចាត់ទុកថា ទោសប្បញ្ញត្តិដែលបានកំណត់ដោយច្បាប់ស្តីពីអ្នកធ្វើការតាមផ្ទះ មានកម្រិតស្រាលពេករហូតដល់មិនអាចធ្វើឲ្យអ្នករំលោភបំពានរាងចាលបានឡើយ។ អ្នកតស៊ូមតិ ក៏បានស្នើឡើងថា ការបង់ថ្លៃសំណងរដ្ឋប្បវេណីឬការខូចខាតនានា អ្នកធ្វើការជាកុមារ គួរតែមានកម្រិតខ្ពស់សម្រាប់អ្នកធ្វើការពេញវ័យ។
- *ការមិនទទួលស្គាល់និងការផ្តល់តម្លៃទាបដល់ការងារតាមផ្ទះ*
  ស្ថានភាពកុមារធ្វើការតាមផ្ទះ មានចំណងជិតស្និទ្ធិទៅនឹងជំហររបស់អ្នកធ្វើការតាមផ្ទះពេញវ័យ ដែលការងាររបស់ខ្លួនត្រូវបានផ្តល់តម្លៃទាបជាប្រចាំ និងមានច្បាប់គ្រប់គ្រងខ្សោយ ហើយដែលភាគច្រើនធ្វើការច្រើនហួសហេតុ បានកម្រៃទាប និងមិនមានការការពារ។ *ការទទួលស្គាល់ការងារតាមផ្ទះ ជា "ការងារពិត" នៅក្នុងគោលនយោបាយការងារថ្នាក់ជាតិនិងគោលនយោបាយសង្គម បង្កើតឲ្យមានក្របខណ្ឌណែនាំមួយ និងជាចំណុចចូលសម្រាប់ដោះស្រាយនិងលុបបំបាត់ពលកម្មកុមារក្នុងការងារតាមផ្ទះ និងដើម្បីផ្តល់ការការពារអ្នកធ្វើការតាមផ្ទះវ័យក្មេងឲ្យបានកាន់តែប្រសើរ។* ដោយសារតែយុទ្ធនាការនិងការបញ្ចុះបញ្ចាំងដ៏ខ្លាំងក្លា ដោយអ្នកតស៊ូមតិដើម្បីសិទ្ធិអ្នកធ្វើការងារតាមផ្ទះនោះ ឥឡូវនេះ មានការកើនឡើងច្បាប់ ក្រឹត្យ និងបទបញ្ញាកម្រិតក្រសួងជាច្រើន នៅថ្នាក់ជាតិ ថ្នាក់ខេត្ត/រដ្ឋ និងថ្នាក់ក្រុង នៅក្នុងទ្វីបអាស៊ីឧទាហរណ៍ នៅក្នុងប្រទេសហ្វីលីពី ហុងកុង ឥណ្ឌា ឥណ្ឌូណេស៊ី និងប្រទេសថៃ